ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលខជ្ជាជីវៈ

លេខ : ០៥៩/១៧ ក.ប/ប្រ.ក. ប.ស.ស

# ប្រកាស
# ស្តីពី
# ការដាក់បញ្ចូលសេវាបន្ថែមសុខភាពនៅក្នុងរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការ កែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/ ០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ-បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ:(០២៣) ៨៨ ២៨ ៦៥

- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ/បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០០៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញប្រកាសលេខ ១០៩ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីការលើកថែទាំសុខភាព
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងដាក់បញ្ចូលសេវាបង្ការសុខភាពនៅក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ។

**ប្រការ ២.-**

សេវាបង្ការសុខភាពដែលត្រូវដាក់បញ្ចូលក្នុងប្រកាសនេះមានដូចខាងក្រោម ៖

១. សេវាចាក់វ៉ាក់សាំងការពារជំងឺឆ្កែឆ្កួត (Rabies Vaccination)

២. សេវាចាក់សេរ៉ូមប្រឆាំងជំងឺឆ្កែឆ្កួត (Antirabic Serum)

៣. សេវាចាក់សេរ៉ូមប្រឆាំងជំងឺតេតាណូស (Anti-Tetanus Serum)

៤. សេវាចាក់សេរ៉ូមប្រឆាំងពិសពស់ (Antivenom Immunoglubulin)

៥. សេវាពិនិត្យឈាមរកជំងឺពក ក មាន៖ TSH (Thyroid-Stimulating Hormone) និង Free T3( Free Triiodothyronine ),Free T4( Free Thyroxine )

៦. សេវាពិនិត្យឈាម កំណត់អបោធាតុមហារីក(Cancer Humeraux Marqueurs) ក្រោយការព្យាបាលជំងឺមហារីកដោយវះកាត់ និង/ឬ ក្រោយការព្យាបាលជំងឺមហារីកដោយចាក់គីមី និង/ឬក្រោយការព្យាបាលជំងឺមហារីកដោយបាញ់កាំរស្មីអ៊ិច មាន៖ CA15-3 (Cancer Antigen15-3), CA19-9 (Cancer Antigen19-9), CA125 (Cancer Antigen125), PSA (Prostate-Specific-Antigen), -HCG (Beta-Human Chorionic Gonadotropin).

សេវាបង្ការដែលបានកំណត់ក្នុងប្រការនេះត្រូវផ្តល់ដោយមូលដ្ឋានសុខាភិបាលសាធារណៈ ឬ វិទ្យាស្ថានសាធារណៈ។

សេវានេះមិនត្រូវបានទូទាត់សងវិញ ចំពោះការប្រើប្រាស់សេវានៅមូលដ្ឋានសុខាភិបាលឯកជន ឬ មន្ទីរពិសោធន៍ឯកជនក្នុង ឬ ក្រៅប្រទេសឡើយ លើកលែងតែមានការអនុញ្ញាតជាមុនពីបេឡាជាតិរបបសន្តិសុខសង្គម។

**ប្រការ ៣ ._**

បេឡាជាតិរបបសន្តិសុខសង្គម ត្រូវទទួលបន្ទុកផ្តល់ និងកំណត់យន្តការទូទាត់ថ្លៃសេវាបង្ការសុខភាពដូចមានចែងក្នុងប្រការ ២នៃប្រកាសនេះ ។

**ប្រការ ៤ ._**

ការកែសម្រួលសេវាបង្ការសុខភាពដូចមានចែងក្នុងប្រការ២ នៃប្រកាសនេះ នឹងត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**ប្រការ ៥ ._**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦ ._**

បេឡាជាតិរបបសន្តិសុខសង្គម កម្មករនិយោជិត និយោជក និងមូលដ្ឋានសុខាភិបាល ឬវិទ្យាស្ថានសាធារណៈដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**__កន្លែងទទួល៖__**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់ក្រសួងពាក់ព័ន្ធ
- សាលារាជធានី-ខេត្ត
  "ដើម្បីជូនជ្រាប"
- គ្រប់អង្គភាពក្រោមឱវាទក្រសួង "ដើម្បីអនុវត្ត"
- សមាគមនិយោជក និងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា
- គ្រប់សហព័ន្ធសហជីព
  "ដើម្បីផ្សព្វផ្សាយ"
- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីផ្សព្វផ្សាយ"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ